**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

# សារលិខិត
# សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
# នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
# ក្នុងឱកាសប្រារព្ធខួបលើកទី២១នៃទិវាជាតិយល់ដឹងអំពីមីន ២៤ កុម្ភៈ ២០២០

*សូមថ្វាយបង្គំព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ!*

*សម្ដេច ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល!*

*ឯកឧត្តម លោកជំទាវ ព្រឹទ្ធាចារ្យ លោកតា លោកយាយ!*

*បងប្អូនជនរួមជាតិទាំងអស់ជាទីស្រឡាញ់រាប់អាន!*

ក្នុងឱកាសដ៏មហោឡារិកប្រារព្ធខួបលើកទី២១នៃទិវាជាតិយល់ដឹងអំពីមីន ២៤ កុម្ភៈ ២០២០ នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំក្នុងនាមរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា សូមសម្តែងនូវក្តីសោមនស្សរីករាយយ៉ាងក្រៃលែងនិងសូមចូលរួមអបអរសាទរខួបលើកទី២១នៃទិវាជាតិនេះ ដែលប្រារព្ធឡើងដើម្បីរំលឹកដល់បងប្អូនជនរួមជាតិទូទាំងព្រះរាជាណាចក្រកម្ពុជា ជាពិសេសបងប្អូនជនរួមជាតិ ដែលកំពុងរស់នៅក្នុងតំបន់រងផលប៉ះពាល់ដោយសារមីន គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាមឲ្យមានការប្រុងប្រយ័ត្នខ្ពស់ចំពោះគ្រោះថ្នាក់ដែលបង្កឡើងដោយសារគ្រាប់ទាំងនោះ។

គ្រាប់មីន គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាម មិនត្រឹមតែបង្កឲ្យប្រជាពលរដ្ឋយើងធ្លាក់ខ្លួនពិការ ស្លាប់បាត់បង់ជីវិតប៉ុណ្ណោះទេ គឺថែមទាំងជាឧបសគ្គសម្រាប់ការស្តារនិងអភិវឌ្ឍន៍ជីវភាពគ្រួសារនិងសេដ្ឋកិច្ចជាតិទៀតផង។ បន្ទាប់ពីកម្ពុជាបានទទួលសុខសន្តិភាព ស្ថិរភាពនយោបាយ សុវត្ថិភាពពេញលេញទូទាំងប្រទេស និងការរួបរួមជាតិពីគ្រប់ភាគីក្រោមនយោបាយ «ឈ្នះ ឈ្នះ» ដោយការធ្វើសមាហរណកម្មអតីតកម្លាំងខ្មែរក្រហមក្នុងមហាគ្រួសារខ្មែរនាឆ្នាំ១៩៩៨ ធ្វើឲ្យរាជរដ្ឋាភិបាលកម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចាត់ចែងបោសសម្អាតមីននៅទូទាំងប្រទេស ដោយក្នុងនោះបានដាក់បញ្ចូលវិស័យមីនទៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា២០១៦-២០៣០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ២០១៩-២០២៣ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ឆ្នាំ២០១៨-២០២៣ ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន២០១៨-២០២៥ និងបានរៀបចំសំណើសុំពន្យារពេលបោសសម្អាតមីនលើកទី២ឆ្នាំ២០២០-២០២៥ ដោយទទួលបានការឯកភាពទាំងស្រុងក្នុងកិច្ចប្រជុំអន្តរជាតិស្តីពីមីននៅទីក្រុងអូស្លូនៃប្រទេសន័រវេស្សក្នុងឆ្នាំកន្លងទៅ។ ទន្ទឹមនេះដែរ ដើម្បីបង្កើនកិច្ចប្រតិបត្តិការបោសសម្អាតមីនឲ្យសម្រេចបានតាមផែនការយុទ្ធសាស្ត្រជាតិ «កម្ពុជាមួយ

គ្មានមីនឆ្នាំ២០២៥» រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចចូលរួមជាថវិកាបដិភាគ១០ភាគរយទៅគ្រប់គម្រោងថ្មីៗសម្រាប់ការបោសសម្អាតមីនដើម្បីមនុស្សធម៌ជាលក្ខណៈទ្វេភាគីឬពហុភាគី និងបានដាក់ចេញនូវផែនការជាក់លាក់ដើម្បីបញ្ចប់ការស្រាវជ្រាវទិន្នន័យជាមូលដ្ឋានចំនួន៧៣ស្រុកនៅខេត្តភាគខាងកើតក្នុងឆ្នាំ២០២០។ ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំបានផ្តល់ការអនុញ្ញាតឲ្យអាជ្ញាធរមីនបន្តប្រជុំពិគ្រោះយោបល់ ពិចារណា និងសិក្សាជាមួយកងយោធពលខេមរភូមិន្ទពីលទ្ធភាពនៃការចូលរួមរបស់កងយោធពលខេមរភូមិន្ទចំនួនប្រមាណ២ ០០០នាក់ ក្នុងប្រតិបត្តិការបោសសម្អាតមីនមនុស្សធម៌ផងដែរ។ ចាប់ពីឆ្នាំ២០២០ដល់ឆ្នាំ២០២៥ កម្ពុជានៅត្រូវការថវិកាប្រមាណ៣៧២លានដុល្លារ ដើម្បីធ្វើការបោសសម្អាតផ្ទៃដីដែលមានមីន៨០៦គីឡូម៉ែត្រក្រឡា ផ្ទៃដីដែលមានគ្រាប់បែកចង្កោម៧០៨គីឡូម៉ែត្រក្រឡា និងផ្ទៃដីដែលមានសំណល់ជាតិផ្ទុះពីសង្គ្រាម៥០៨គីឡូម៉ែត្រក្រឡា។

សកម្មភាពបោសសម្អាតមីន គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាម ជាលក្ខណៈមនុស្សធម៌នៅកម្ពុជាមានរយៈពេល២៧ឆ្នាំ(១៩៩២-២០១៩)។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៩ បានរំដោះផ្ទៃដីមានមីនបានប្រមាណចំនួន១ ៩៧៩ ៤៧៦ ៦២៣ម៉ែត្រក្រឡា រកឃើញនិងកម្ទេចចោលគ្រាប់មីនប្រឆាំងមនុស្សចំនួន១ ០៨០ ៨១៤គ្រាប់ មីនប្រឆាំងរថក្រោះចំនួន២៥ ១៨៦គ្រាប់ គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាមចំនួន២ ៨៣២ ៦២៦គ្រាប់។ លទ្ធផលដូចបានរៀបរាប់មកនេះ បានធ្វើឲ្យចំនួនជនរងគ្រោះថយចុះពីចំនួន៤ ៣២០នាក់ ក្នុងឆ្នាំ១៩៩៦ មកត្រឹមចំនួន៧៧នាក់ ក្នុងឆ្នាំ២០១៩កន្លងទៅ។

សមិទ្ធផលដ៏ធំធេងទាំងនេះ ពិតជាប្រសូតចេញពីកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់រាជរដ្ឋាភិបាលកម្ពុជា ប្រទេសជាមិត្ត ដៃគូអភិវឌ្ឍន៍ និងប្រតិបត្តិករជាតិនិងអន្តរជាតិ ក្នុងការរំដោះផ្ទៃដីជូនប្រជាពលរដ្ឋប្រើប្រាស់ បង្កបង្កើនផល ធ្វើស្រែចម្ការ កសាងភូមិដ្ឋាន កសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈនានា កាត់បន្ថយជនរងគ្រោះថ្នាក់ដោយសារមីន និងរួមចំណែកកាត់បន្ថយភាពក្រីក្រ។ ទោះបីយ៉ាងណាក៏ដោយមីន គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាម នៅតែជាការគំរាមកំហែងចំពោះប្រជាពលរដ្ឋនិងជាឧបសគ្គដល់ការអភិវឌ្ឍ ដូចជានៅក្នុងឆ្នាំ២០១៩កន្លងទៅនេះ អត្រាជនរងគ្រោះមានការកើនឡើងចំនួន៣៣ភាគរយ ប្រៀបធៀបទៅនឹងអត្រាគ្រោះថ្នាក់នៅឆ្នាំ២០១៨។

***ជនរួមជាតិជាទីស្នេហា!***

ថ្វីបើការបោសសម្អាតមីនបាននឹងកំពុងទទួលលទ្ធផលយ៉ាងធំធេងយ៉ាងណាក៏ដោយ ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាម នៅតែដើរតួយ៉ាងសំខាន់ក្នុងវិស័យសកម្មភាពមីនក្នុងការទប់ស្កាត់អត្រាគ្រោះថ្នាក់ដែលបង្កឡើងដោយសារមីន គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាម តាមរយៈការជំរុញសកម្មភាពអប់រំមីនដោយផ្ទាល់នៅតាមសហគមន៍ ការលេងកីឡា ការផ្សព្វផ្សាយទូលាយតាមវិទ្យុ ទូរទស្សន៍ បណ្តាញសង្គម ផ្ទាំងប៉ាណូ ខិត្តប័ណ្ណ និងរហូតដល់ការបញ្ចូលសារអប់រំអំពីមីនទៅក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវ និងវិធានការរដ្ឋបាលនានាថែមទៀត។

ក្នុងឱកាសប្រារព្ធខួបលើកទី២១នៃទិវាជាតិយល់ដឹងអំពីមីន ២៤ កុម្ភៈ នេះ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមធ្វើការអំពាវនាវដល់អាជ្ញាធរមីន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកម្លាំងប្រដាប់អាវុធ ប្រតិបត្តិករជាតិ និងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ ព្រមទាំងប្រជាពលរដ្ឋ ដូចតទៅ៖

១-អាជ្ញាធរមីនដែលជាសេនាធិការរាជរដ្ឋាភិបាលលើវិស័យសកម្មភាពមីនត្រូវរៀបចំសម្របសម្រួលជាមួយប្រតិបត្តិករអប់រំមីន និងភាគីពាក់ព័ន្ធជាតិនិងអន្តរជាតិ ដើម្បីជំរុញសកម្មភាពអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាម ក្នុងគោលដៅកំណត់ឲ្យបានជាក់លាក់នូវតំបន់ឬទីតាំងដែលរងការប្រឈមគ្រោះថ្នាក់ដោយសារមីន គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាម ព្រមទាំងធ្វើការអប់រំទប់ស្កាត់គ្រោះថ្នាក់។

២-អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវចូលរួមសហការសម្របសម្រួលលើកទឹកចិត្តដល់ប្រតិបត្តិករជាតិ និងអន្តរជាតិ និងអង្គការពាក់ព័ន្ធ ដើម្បីគាំទ្រនិងជំរុញការអនុវត្តកម្មវិធីអប់រំយល់ដឹងអំពីមីនដល់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

៣-អាជ្ញាធរមានសមត្ថកិច្ចនិងអាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ត្រូវចូលរួមផ្សព្វផ្សាយជាប្រចាំ តាមរយៈគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋអំពីគ្រោះថ្នាក់ដោយសារមីន គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាម ជាពិសេសពង្រឹងលើការអនុវត្តច្បាប់ស្តីពីការគ្រប់គ្រងអាវុធគ្រឿងផ្ទុះនិងគ្រាប់រំសេវ។

៤-ប្រតិបត្តិករអប់រំយល់ដឹងអំពីមីនជាតិនិងអន្តរជាតិ និងភាគីពាក់ព័ន្ធ ត្រូវចូលរួមឲ្យបានខ្លាំងក្លាថែមទៀត ក្នុងការផ្សព្វផ្សាយការអប់រំយល់ដឹងអំពីគ្រោះថ្នាក់ដោយសារមីន គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាមដល់ប្រជាពលរដ្ឋ ជាពិសេសជនងាយរងគ្រោះក្នុងសហគមន៍ សិស្សានុសិស្ស កុមារា កុមារី និងយុវជនក្រៅសាលា។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំក៏សូមអំពាវនាវដល់បងប្អូនជនរួមជាតិទាំងអស់ មេត្តាចូលរួមអនុវត្តដូចខាងក្រោម៖

- បងប្អូនកូនក្មួយ ដែលបានជួបប្រទះមីន គ្រាប់បែកចង្កោម ឬសំណល់ជាតិផ្ទុះពីសង្គ្រាម សូមកុំប៉ះពាល់គ្រាប់ទាំងនោះជាដាច់ខាតហើយត្រូវរាយការណ៍ជាបន្ទាន់ដល់អាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរមូលដ្ឋានឬប្រតិបត្តិករបោសសម្អាតមីនដែលនៅជិតបំផុត
- ហាមទិញ លក់ រក្សាទុក កែច្នៃមីន គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាម ដែលជាអំពើល្មើសច្បាប់
- ត្រូវសាកសួរអាជ្ញាធរឬអ្នកដែលដឹងច្បាស់អំពីព័ត៌មានក្នុងតំបន់ដែលបងប្អូនកូនក្មួយមានបំណងប្រើប្រាស់ដីទាំងនោះ ធ្វើដំណើរឆ្លងកាត់ ឬរុករកអនុផលព្រៃឈើ
- មិនត្រូវប្រើប្រាស់គ្រឿងចក្រធុនធ្ងន់រុករានដីដែលមិនទាន់បានធ្វើការបោសសម្អាតមីន គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាមរួច។

ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមឆ្លៀតឱកាសដ៏មហោឡារិកនេះ សម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ និងស្មោះស្ម័គ្របំផុតជូនចំពោះប្រទេសជាមិត្ត ដៃគូអភិវឌ្ឍន៍ បណ្តាអង្គការជាតិនិងអន្តរជាតិ និងប្រតិបត្តិករសកម្មភាពមីនទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ក្នុងបេសកកម្មបោសសម្អាតមីននៅព្រះរាជាណាចក្រកម្ពុជា ដើម្បីសង្គ្រោះជីវិត កាត់បន្ថយគ្រោះថ្នាក់ និងលើកកម្ពស់សុវត្ថិភាពជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាយើងខ្ញុំឲ្យបានប្រសើរជាលំដាប់ រួមចំណែកស្តារនិងអភិវឌ្ឍសេដ្ឋកិច្ចជាតិឲ្យកាន់តែរុងរឿងឆាប់រហ័សថែមទៀត។ ទូលព្រះបង្គំ ខ្ញុំព្រះករុណា ខ្ញុំសូមថ្វាយព្រះពរ និងប្រគេនពរ សម្តេចព្រះសង្ឃរាជ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សម្តេច ឯកឧត្តម លោកជំទាវ ព្រឹទ្ធាចារ្យ លោកតា លោកយាយ និងជូនពរបងប្អូនកូនក្មួយជនរួមជាតិទាំងអស់ សូមប្រកបដោយពុទ្ធពរ ទាំងបួន ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

ថ្ងៃ ពុធ ៤រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ២០២០

**ហ៊ុន សែន**